អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១

## សេចក្តីប្រកាសព័ត៌មាន
## អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធសេចក្តីសម្រេច
## របស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែង អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំង

ថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទទួលយកបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាដោយមតិភាគច្រើនលើសលុប ដោយសម្រេចបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលចេញនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១១ ដែលបានបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌនោះ។

អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវវិធានការនានាដែលមាន ដើម្បីអាចជួយធ្វើឲ្យជនជាប់ចោទមានសម្បទាចូលរួមក្នុងសវនាការបាន។ សេចក្តីសម្រេចនេះ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើលទ្ធភាព ទោះបីជាមានតិចតួចក៏ដោយ ក៏ជាការធ្វើឲ្យប្រសើរឡើងវិញដ៏សមស្របមួយ ចំពោះសុខភាពផ្នែកស្មារតីរបស់ជនជាប់ចោទដែលត្រូវបានប្រមើលមើលឃើញដោយអ្នកជំនាញវេជ្ជសាស្ត្រ ដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង។ ក្នុងស្ថានភាពដែលការផ្អាកកិច្ចដំណើរការនីតិវិធី អាចត្រូវបានផុតរលត់នោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការដោះលែងជនជាប់ចោទដោយឥតលក្ខខណ្ឌ មិនតម្រូវឲ្យមានឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មូលដ្ឋានដែលមានពីមុនមកក្នុងការរក្សាទុកជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន ត្រូវមានសុពលភាពដដែល ពោលគឺធានាវត្តមានរបស់ជនជាប់ចោទក្នុងអំឡុងពេលសវនាការ។

អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ថា អង្គជំនុំជម្រះសាសាដំបូង ដោយមានការពិភាក្សាជាមួយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ និងផ្នែកវិកលចរិកសមស្រប ត្រូវស្នើឲ្យមានការព្យាបាលបន្ថែមដល់ជនជាប់ចោទដែល

អាចជួយឲ្យសុខភាពផ្នែកស្មារតីរបស់ជនជាប់ចោទបានប្រសើរឡើង ដើម្បីឲ្យជនជាប់ចោទអាចមានសម្បទាចូលរួមសវនាការបាន។ ការព្យាបាលនេះត្រូវតែធ្វើឡើងនៅក្នុងមន្ទីរពេទ្យ ឬកន្លែងដទៃទៀតដែលសមស្រប នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជនជាប់ចោទត្រូវទទួលការត្រួតពិនិត្យពីអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ផ្នែកវិកលចរិក និង/ឬផ្នែកចិត្តសាស្ត្រ មិនឲ្យលើសពីរយៈពេល ៦ (ប្រាំមួយ)ខែ ចាប់គិតពីពេលចាប់ផ្តើមការព្យាបាលមក បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់អំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការដោយមិនមានការពន្យាពេល។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការឃុំខ្លួនជនជាប់ចោទត្រូវអនុវត្តនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់ពេលការរៀបចំចាត់ចែងចាំបាច់នានា សម្រាប់ការព្យាបាលបន្ថែមនៅក្នុងមន្ទីរពេទ្យ ឬកន្លែងសមស្របដទៃទៀត ត្រូវបានបំពេញរួចរាល់ ។

សេចក្តីសម្រេចទាំងស្រុងមាននៅលើគេហទំព័រនៃ អ.វ.ត.ក ៖
http://www.eccc.gov.kh/en/document/court/decision-immediate-appeal-against-trial-chamber039s-order-release-accused-ieng-thirit

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(0)១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥ (0)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៣ ២៨៣
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh